# កំណាព្យអប់រំ

## សម្រាប់ទិវាគ្រូបង្រៀន

## ៨ តុលា ឆ្នាំ ២០១៩



ដោយ បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

២០១៩

# កំណាព្យអប់រំ

## សម្រាប់ទិវាគ្រូបង្រៀន

## ៥ តុលា ឆ្នាំ ២០១៩

# កំណាព្យអប់រំ

## សម្រាប់ទិវាគ្រូបង្រៀន
## ៥ តុលា ឆ្នាំ ២០១៩

ដោយ បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

២០១៩

© ហង់ជួន ណារ៉ុន
រក្សាសិទ្ធិគ្រប់យ៉ាង

បោះពុម្ពនៅកម្ពុជាដោយរោងពុម្ព អេស អេច

# មាតិកា

អារម្ភកថា..... ៧
អារម្ភកថា..... ៨
គុណគ្រូ......... ១០
គ្រូជាវិស្វករព្រលឹង ១១
គរុនិស្សិតវិទ្យាស្ថានជាតិអប់រំ ១២
ប្រព័ន្ធកុំព្យូទ័រកិច្ចការប្រឡង ១៣
ប្រជុំគណៈរដ្ឋមន្ត្រី ១៤
ព្រះវិហារដែនដីស្រីសិខរិស្វរៈ ១៥
ខ្ញុំជាអប្បមាទ ១៦
ការអប់រំតាមបែបឌីជីថល ១៧
វិទ្យាស្ថានគរុកោសល្យភ្នំពេញ ១៨
វិទ្យាស្ថានគរុកោសល្យបាត់ដំបង ១៩
មាគ៌ាទៅកាន់អង្គរ ២០
អ្នកចេះគឺជាប់ ២១
អាទិភាពកំណែទម្រង់អប់រំ ២២
កំណាព្យជូនពរកូនស្រី ហង់ វិមលា ២៣
វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ ២៤
គរុសិស្សកំពង់ស្ពឺ ២៥
ក្រុងព្រះសីហនុ ២៦
គរុសិស្សខេត្តកំពត ២៧
សាលាគរុកោសល្យខេត្តតាកែវ ២៨
គរុសិស្សកំពង់ធំ ២៩

គរុសិស្សខេត្តស្ទឹងត្រែង ........ ៣០
គរុសិស្សខេត្តក្រចេះ ........ ៣១
គរុសិស្សខេត្តកំពង់ចាម ........ ៣២
គរុសិស្សខេត្តព្រៃវែង ........ ៣៣
គរុសិស្សខេត្តស្វាយរៀង ........ ៣៤
គរុសិស្សខេត្តកណ្ដាល ........ ៣៥
ជូនពរបេក្ខជនប្រឡង ........ ៣៦
ប្រធានមណ្ឌល ........ ៣៧
ជំនួយការអប្បមាទ ........ ៣៨
អនុរក្សក្នុងពេលប្រឡង ........ ៣៩
អាទិភាពទាំង ៨ នៃកំណែទម្រង់វិស័យអប់រំ ........ ៤០
គ្រូជាមូលដ្ឋានគ្រឹះនៃយុគសម័យឌីជីថល ........ ៤២
Partir c'est mourir un peu! ........ ៤៤
បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ........ ៤៥
ស្នាដៃរបស់អ្នកនិពន្ធ ........ ៤៩

# អារម្ភកថា

(**បទពាក្យ ៨ សុត្តន្តប្រីជា តន្ទ**)

| | | |
|---|---|---|
| សូមគោរព | ញាតិមិត្ត | ទាំងប្រុសស្រី |
| សូមសន្តោស | ប្រណី | ដល់រូបស្មេរ |
| ប្រសិនបើ | មានខុស | ការសរសេរ |
| ដោយសារស្មេរ | ទើបរៀន | សរសេរកាព្យ។ |
| | | |
| កើតជាខ្មែរ | នៅតែ | មានមោទន |
| បានរតន | សម្បត្តិ | សម្បូណ៌កាវ្យ[1] |
| ជូនតាផ្ដល់ | បន្សល់ | ទុកកំណាព្យ |
| ដូចសំណាប | ខែស្រាពណ៍ | ស្រស់គ្មានពីរ។ |
| | | |
| អក្សរសិល្ប៍ | សិល្បៈ | សម្បូណ៌ណាស់ |
| វប្បធម៌ចាស់ | ជាងគេ | នៅអាស៊ី |
| ខ្មែរត្រូវខំ | រក្សា | យ៉ាងសំគី |
| ដូចទេពី | ច្បុតពី | ឋានត្រៃត្រឹង។ |

ភ្នំពេញ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៩

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

---

1 កាវ្យ ៖ ជាពាក្យសំស្ក្រឹត មានន័យថា «កាព្យ»។

# អារម្ភកថា

(**បទកាកគតិ**)

សូមលើកហត្ថា រំឭកឧបការ លោកអ្នកមានគុណ
បិតាមាតា ប្រសើរលើសលន់ មហាសែនធ្ងន់
លើទ្វីបលោកា។

ព្រះនាម ហង់ជួន ប្រាជ្ញាមាំមួន ទឹកចិត្តស្នេហា
ក្រោយថ្ងៃរំដោះ ប្រាំពីរមករា ស្តារខឿនសិក្សា
អប់រំឡើងវិញ។

ពេលនេះបន្ត តំណែងតំណ បិតាបំពេញ
ជារដ្ឋមន្ត្រី អប់រំពេញលេញ ប្រៀបចិត្តពោរពេញ
ដោយក្តីមោទនៈ។

ប្រាំឆ្នាំកន្លង កិច្ចការប្រឡង បានជោគជ័យជាក់
កំណែទម្រង់ បន្ថយឧបសគ្គ មិនទៅស្ទើរស្ទាក់
លាន់ឮដូចផ្គរ។

ដំណើរទៅមុខ ជនជានឈានមុខ មូលដ្ឋានគាំទ្រ
សាងជំនាន់ថ្មី ពូជពង្សអង្គរ ទូទាំងនគរ
ជានាស្តុកស្តម្ភ។

ធ្វើច្រើនឈប់តិច បំពេញភារកិច្ច រិះគិតរៀបចំ
ស៊ូទ្រាំនឿយហត់ អំណត់លត់ដំ ជ្រោងសសរស្តម្ភ
អប់រំប្រសើរ។

សតវត្សរ៍២១ ត្រូវពូនជ្រំជ្រួយ សមត្ថភាពប្រើ
បច្ចេកវិទ្យា ជំនាញបម្រើ សព្វការសារពើ
ជាឌីជីថល។

វិនិយោគអប់រំ ជាធនធានធំ ជូនជាតិសកល
ជំរុញបង្កើន សមិទ្ធិផល មិនអាចស្កប់ស្កល់
នាយុគសម័យ។

សូមកោតសរសើរ ចពោះដំណើរ ប្រឡងថ្មីៗ
លោកគ្រូអ្នកគ្រូ គរុសិស្សក្ដី រួមមានស្នាដៃ
ទុកជាសាវតារ។

អប្បមាទជំនួយ អនុរក្សប្រឹងជួយ ទាន់សភាពការណ៍
គ្មានលួចចម្លង គ្មានយកឯកសារ សុវត្ថិវិញ្ញាសា
គ្មានការបែកធ្លាយ។

អរគុណ អរគុណ ភារកិច្ចធ្ងន់ យើងបានរែកស្ពាយ
លទ្ធផលប្រឡង ឆ្នាំនេះពណ្ណរាយ ប្រជារីករាយ
ទទួលសាទរ។

កុសលខ្ញុំសាង សូមជូនសំណាង សួស្ដីបវរ
គ្រប់ផ្នែកពាក់ព័ន្ធ និង អ ប ព គោរពជូនពរ
ជោគជ័យគ្រប់គ្រា។

*ទីស្ដីការក្រសួងអប់រំ យុវជន និងកីឡា ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៩*

*លោកជំទាវ* ***ទន់ សាអ៊ីម***

*អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា*

# គុណគ្រូ

(បទសារថីទាញរថ)

រៀនសូត្រផ្តល់ ផលចំណេះ ចេះរៀនសូត្រ
សម្បត្តិលួត ក្ជូតមិនបាន មានសម្បត្តិ
ជាធនធាន មានបានជាតិ ទៀតជាធន
ហ៊ានវែកពុន គុណចំពោះ ព្រោះហ៊ានវែក។

គុណគ្រូធំ សូមចង់ចាំ ផ្តាំគុណគ្រូ
គ្រូវែកស៊ូ គ្រូបង្រៀន រៀនគ្រូវែក
រៀនចេះគ្រប់ ភពលោករស់ ព្រោះរៀនចេះ
ពុទ្ធិកើន ច្រើនព្រោះគ្រូ គ្រូពុទ្ធិ។

ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩

# គ្រូជាវិស្វករព្រលឹង

(បទពាក្យ ៧)

គ្រូជាវិស្វករព្រលឹង គ្រូជាពំនឹងកែសង្គម
បណ្តុះស្មារតីជាតិនិយម ខ្មែរយើងថ្កើងថ្កុំជាអមតៈ។

គ្រូជាអ្នកកែច្នៃវាសនា ជនជាតិខេមរាស្គាល់សច្ចៈ
ចេះសាមគ្គីគ្នាដោយស្មោះស្ម័គ្រ ពុទ្ធិប្រចក្សដើម្បីជាតិ។

តែងសម្រាប់ពិធីបញ្ចុះបឋមសិលាសាងសង់អគារ
នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកណ្តាល
ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩

# គរុនិស្សិតវិទ្យាស្ថានជាតិអប់រំ

(បទពាក្យ ៤)

គរុនិស្សិត ជំនាន់ ២៤
ខិតខំខ្ជាប់ខ្ជួន ត្រេបយកវិជ្ជា។

សិក្សាស្រាវជ្រាវ ឱ្យក្លាយទៅជា
គ្រូមាននាមា បង្រៀនមោះមុត។

គរុកោសល្យ គឺជាអាវុធ
គ្រូខំហាត់ពត់ សំលៀងរាល់ថ្ងៃ។

សិក្សារិះរក ប្រឌិតកែច្នៃ
សិស្សមានស្នាដៃ មានចំណេះខ្ពស់។

ថ្ងៃនេះថ្ងៃចន្ទ ល្អប្រពៃឈ្មោះ
ទាំងស្រីទាំងប្រុស ខិតខំបង្ហាញ។

ឱ្យឃើញស្នាដៃ ដែលខ្លួនខំត្បាញ
ស្រាវជ្រាវស្ទិតស្ទាញ រដ្ឋមន្ត្រីបានឃើញ។

តែងក្នុងឱកាសពិព័រណ៍ស្នាដៃគរុនិស្សិតជំនាន់ទី២៤នៅវិទ្យាស្ថានជាតិអប់រំ
ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៩
ហាងកាហ្វេ The Shop

# ប្រព័ន្ធកុំព្យូទ័រកិច្ចការប្រឡង

(បទពាក្យ ៦)

ប្រព័ន្ធកុំព្យូទ័រថ្មី បងស្រីខិតខំកសាង
បញ្ចូលពិន្ទុគ្រប់យ៉ាង សំអាងកំណែទម្រង់។

ឆ្នាំនេះមាន software ថ្មី បងស្រីធ្វើការទ្រទ្រង់
មានភាពដឹកនាំពូជពង្ស ទម្រង់ការងារបានល្អ។

យើងខ្ញុំគាំទ្រស្មោះសរ តំណាទៅបានផលធំ
ប្រព័ន្ធទិន្នន័យមូលផ្តុំ ឆ្លងសុំយោបល់សម្រេច។

ការងារប្រឡងចាំបាច់ បានស្រេចឆ្នាំនេះជាម្តង
ជំរុញរៀបចំចងក្រង ត្រូវឆ្លងសម្រេចស្ថាពរ។

ការនេះពិតជាធ្ងន់ធ្ងរ គាំទ្រលម្អិតចម្រាញ់
ខ្ញុំដឹងថាមិនសាមញ្ញ បើចាញ់មានហានិភ័យ។

សម្រាប់ការប្រជុំសម្រេចប្រព័ន្ធកុំព្យូទ័រ
ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩
ទីស្តីការក្រសួងអប់រំ យុវជន និងកីឡា

# ប្រជុំគណៈរដ្ឋមន្ត្រី
(បទពាក្យ ៧)

ថ្ងៃនេះជាថ្ងៃនក្ខត្តឫក្ស ជួបគ្នាពីព្រឹកពិភាក្សា
គោលនយោបាយ និងផែនការ ការពារប្រជាអ្នកប្រើប្រាស់។

ក្រោមអធិបតីសម្តេច ហ៊ុន សែន ជាកាពីតែនមានតេជះ
ពិភាក្សាកំណត់យុទ្ធសាស្ត្រ ឱ្យប្រជារាស្ត្រមានឥណទាន។

យុគពាណិជ្ជកម្មសម័យថ្មី ប្រជាប្រុសស្រីប្រើធនធាន
អេឡិចត្រូនិចទស្សនទាន អន្តរកម្មឈានតាមវិធី។

ចម្បងការងារត្រូវសាងសង់ ទុកជាសំណង់ឥតមានពីរ
ដើម្បីផលិតអគ្គិសនី សូរ្យសែងជាទីថាមពលខ្លាំង។

តែងសម្រាប់ការប្រជុំគណៈរដ្ឋមន្ត្រីដើម្បីអនុម័ត
គោលនយោបាយជាតិស្តីពីគោលនយោបាយជាតិការពារអ្នកប្រើប្រាស់
ប្រព័ន្ធហិរញ្ញវត្ថុបរិយាប័ន្ន សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្ម
អេឡិចត្រូនិច និងគម្រោងផលិតអគ្គិសនីដើរដោយរស្មីព្រះអាទិត្យ។
ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩
នៅទីស្តីការគណៈរដ្ឋមន្ត្រី

# ព្រះវិហារដែនដីស្រីសិខរិស្វរៈ

(បទពាក្យ ៧)

១- ប្រាសាទអណ្ដែតលើវេហា ដាស់ជនខេមរាឱ្យចងចាំ
ថាខ្មែរពីមុនតាមចំណាំ ជាពូជធ្លាប់ខ្លាំងមានតេជះ។

២- ខ្មែរខ្លាំងដោយខ្មែរមានចំណេះ ខ្មែរចេះរិះគ្រិះមានជម្នះ
សិក្សារៀនសូត្រយ៉ាងរូតរះ ហើយធ្លាប់ច្បាំងឈ្នះសត្រូវមារ។

៣- គរុសិស្សរួមអ្នកចងចាំថា ប្រជាខេមរាគ្រប់ៗគ្នា
កំពុងរង់ចាំគ្រប់វេលា ឱ្យអ្នកគ្រប់គ្នាមើលប្រឡង។

៤- អប្បមាទអនុវត្តភារកិច្ចធំ គុណភាពអប់រំជាចម្បង
កំណែទម្រង់ការប្រឡង បេក្ខជនត្រាប់ត្រង់តាមបញ្ញត្តិ។

៥- ឱត្បែងមានជ័យស្រស់បវរ ព្រះវិហារល្អប្រតិបត្តិ
ជួបហើយមិនចង់ឃ្លាតឃ្លាបាត់ ព្រោះមិនចង់ព្រាត់ពីកនិដ្ឋា។

ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង៩:៣០នាទី
តាមរថយន្តពីខេត្តកំពង់ធំទៅខេត្តព្រះវិហារ

# ខ្ញុំជាអប្បមាទ

(បទពាក្យ ៨)

១- ខ្ញុំជាអប្បមាទនៅពេលប្រឡង បំពេញតាមកម្រងភារកិច្ច
ខិតខំប្រឹងប្រែងធ្វើមិនដែលភ្លេច គឺជាកាតព្វកិច្ចដើម្បីខ្មែរ។

២- កំណែទម្រង់ឱ្យមានគុណភាព ឱ្យយុវជនយើងជ្រាប និងពូកែ
ជាពូជសាសន៍ធ្លាប់ខ្លាំងនឹងគេដែរ យើងប្រឹងឱ្យខ្មែរមល្បីកេរ្តិ៍ឈ្មោះ។

៣- កើតមកជាតិនេះមិនដែលសោកស្តាយ សូមអភិប្រាយដោយកិត្តិយស
កើតជាខ្មែរទៀតជាតិធ្លាប់ខ្ពង់ខ្ពស់ រុងរឿងខ្មែររស់ពូជពង្សអង្គរ។

៤- ខ្ញុំធ្វើដោយការទទួលខុសត្រូវ ប្រឡងនាំមកនូវគុណភាពល្អ
ខ្ញុំនឹងធ្វើដោយចិត្តស្មោះសរ អនាគតល្អកូនខ្មែររុងរឿង។

វេលាម៉ោង៨:៥០នាទី ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩
តាមរថយន្តពីកំពង់ឆ្នាំងទៅពោធិ៍សាត់

# ការអប់រំតាមបែបឌីជីថល

(បទពាក្យ ៩)

*បដិវត្តន៍ ឌីជីថល មកដល់ហើយ កូនខ្មែរអើយ ត្រូវខិតខំ រៀនIT*
*ដើម្បីក្លាយ ជាធនធាន ឥតមានពីរ ត្រូវសំកី ចេះIT គ្រប់ៗគ្នា។*

*រៀន Coding ជាបំណិន សម័យថ្មី ខ្មែរប្រុសស្រី ត្រូវឃ្លាតខ្លី ក្រេបវិជ្ជា*
*មានចំណេះ មានបំណិន មានចរិយា ទាំងអស់គ្នា ក្លាយទៅជា មូលធន។*

*ការអប់រំ ឌីជីថល សម័យនេះ ត្រូវត្រិះរិះ ត្រូវដោះស្រាយ ការស្រាលធ្ងន់*
*ចេះបង្កើត អនុវត្ត បង្កើនគុណ យុវជន ប្រទេសជាតិ មាតុភូមិ។*

*ដូច្នេះគ្រូ ត្រូវផ្លាស់ប្តូរ វិធីសាស្ត្រ ពិសេសណាស់ឱ្យសិស្សមានបំណិនBloom*
*កម្មវិធី បែបបញ្ញត្តិ ពិតយល់ព្រម បំណិនBloom រៀនឱ្យចេះ ចេះធ្វើថ្មី។*

*សម្រាប់សម្ពោធដាក់ឱ្យប្រើប្រាស់បន្ទប់ព័ត៌មានវិទ្យា*
*នៅសាលាបឋមសិក្សាបាក់ទូក*
*(ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩)*
*ហាង់កាហ្វេ Spoon*

# វិទ្យាស្ថានគរុកោសល្យភ្នំពេញ

(បទពាក្យ ៩)

១- វិទ្យាស្ថាន គរុកោ សល្យភ្នំពេញ
មិនទោម្នេញ នឹងក្រេបយក ចំណេះដឹង
ជួយគរុ សិស្សនិស្សិត ឱ្យខំប្រឹង
ហើយរំពឹង ថានឹងក្លាយ ជាបញ្ញវន្ត។

២- កំណែទំ- រង់អប់រំ ជាប្រព័ន្ធ
មិនធុញទ្រាន់ នឹងគាំទ្រ ជាសារវន្ត
ឱ្យសិស្សចេះ គ្រូខំប្រឹង ហើយរៀនទាន់
នេះគឺគ្រាន់ ការប្រឡង មានគុណភាព។

៣- បដិវត្តន៍ ឌីជីថល គួរអ្នកជ្រាប
ជារៀងរាប ហើយទាមទារ ផលិតភាព
ចិត្តមាយាទ ច្នៃប្រឌិត គិតធ្វើថ្មី។

៤- យើងជាធន ធានកម្រ គួរបេតី
ទាំងប្រុសស្រី ត្រូវចូលរួម កសាងជាតិ
ខ្មែររុងរឿង ក្បែរមហ៊ុំថ្កើង មិនឃ្លាឃ្លាត
ក្រោយវិវាទ ខ្មែរយើងបើក សករាជថ្មី។

ថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង៣:០០នាទីរសៀល

# វិទ្យាស្ថានគរុកោសល្យបាត់ដំបង

(បទពាក្យ ១០)

១- វិទ្យាស្ថានគរុកោសល្យបាត់ដំបង បានចងចំណងបងជាប់នឹងស្រស់ស្រីថ្ងៃ
អូនជាបុប្ផាស្ទឹងសង្កែល្អពេកក្រៃ បងជាមន្ត្រីនៃស្ថាប័នគ្រូឧទ្ទេស។

២- យុវនារីជីវីបន្តការសិក្សា យកបរិញ្ញាតាមគោលការណ៍កែទម្រង់
ចៅចិត្រខំបំពេញការងារយ៉ាងផ្ចិតផ្ចង់ តាមវិធីតម្រង់ត្រិះរិះពិចារណា។

៣- កម្មវិធីសិក្សាថ្មីតាមបែបបញ្ញត្តិ បងប្រតិព័ទ្ធអូនស្ងាត់ៗទើបវាចា
ស្រឡាញ់បុប្ផាស្ទឹងសង្កែយូរហើយណា ឱយុវជីវ៉ា តើចិន្តាស្នេហ៍បងទេ។

៤- រៀមបងយកវត្តពោធិវាលធ្វើជាសាក្សី បង្ហាញហឫទ័យថាស្ម័គ្រនឹងមាសមេ
ចង់លើកស្លួយកិត្តិយសផ្កាស្ទឹងសង្កែ ថ្នមរក្សាថែសមិទ្ធិកែទម្រង់។

ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង០៧:៤៥ព្រឹក
តាមរថយន្តពីខេត្តបាត់ដំបងទៅខេត្តបន្ទាយមានជ័យ

# មាគ៌ាទៅកាន់អង្គរ

(*បទពាក្យ ១១*)

*១- ប្រាសាទអង្គរស្រស់បវរក្នុងពិភពលោក មានជ័យជោគជាមោទនរបស់ជនជាតិខ្មែរ*
*កេរដូនតាត្រូវអភិរក្ស និងរក្សាថែ ឱ្យកូនខ្មែរចេះអាល័យស្នាដៃពីបុរាណ។*

*២- អក្សរថ្មធ្លាក់ជាប់ក្នុងបេះដូងរបស់គ្រូ ត្រូវតស៊ូដើម្បីអនាគតយើងថ្កើងថ្កាន*
*សមិទ្ធិកំណែទម្រង់មិនដែលនឹកស្មាន ថានឹងមានលទ្ធផលល្អដូចថ្ងៃនេះ។*

*៣-មាគ៌ាទៅអង្គរដូចជាឋានតុសិតថ្មី ជាវិថីមានសាលាបង្រៀនផ្ដល់ចំណេះ*
*ឱ្យកូនខ្មែរជាគ្រាប់ពូជអង្គរដុះចាក់ស្រេះ គ្រូយើងចេះផ្ដល់ចំណេះតាមបែបរិះរកថ្មី។*

*៤- ឱសំឡេងវៃ! ឱក្ងិនរំដួល! រំដួលចិត្ត ក្រអូបឆ្ងិតពិតឱ្យចិត្តនៃបនិត្យស្មោះស្ម័គ្រមេត្រី*
*សាលាគរុកោសល្យពីរោះដូចតន្ត្រី រដ្ឋមន្ត្រីបណ្ដុះស្មារតីជាអប្បមាទ។*

*ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង១០:០០ព្រឹក*
*តាមរថយន្តពីខេត្តបន្ទាយមានជ័យទៅខេត្តសៀមរាប*

# អ្នកចេះគឺជាប់

(បទកាកគតិ)

រដូវប្រឡង ដែលសិស្សយើងប៉ង បានមកដល់ហើយ
ទាំងប្រុសទាំងស្រី កុំនៅកន្តើយ រៀនសូត្រមិនស្បើយ
ដើម្បីអនាគត។

រៀនគ្រប់វិជ្ជា ដែលបានសិក្សា ឱ្យបានគត់មត់
អ្នកចេះគឺជាប់ តាំងចិត្តមោះមុត មិនត្រូវសម្រុត
ដើម្បីគុណភាព។

មិនត្រូវបើកចាក់ ព្រោះនេះជាផ្លាក់ គ្រោះអសមត្ថភាព
ចំណេះជាទ្រព្យ ប្រើគ្រប់ស្ថានភាព ហើយទុកជាលាភ
តកូនតចៅ។

ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៩

# អាទិភាពកំណែទម្រង់អប់រំ

(***បទកាកគតិ***)

*១- ខ្ញុំលើកហត្ថា ដើម្បីវន្ទនា ដោយក្តីគោរព*
*ខ្ញុំមានកិត្តិយស បានមកប្រសព្វ ឱ្យជ្រាបសព្វគ្រប់*
*ពីការអប់រំ។*

*២- ខ្ញុំសូមជម្រាប ថាអាទិភាព របស់យើងខ្ញុំ*
*គឺកុមារតូច និងកុមារធំ អាហារូបត្ថម្ភ*
*ជាគ្រឹះចំណេះ។*

*៣- អំណានដំបូង គណិតដំបូង រៀនហើយឱ្យចេះ*
*កម្រិតបឋម រៀនមានតម្រិះ ឱ្យចេះត្រិះរិះ*
*និងមានបំណង។*

*៤- កំណែទម្រង់ ពួកយើងកំពុង ពង្រឹងគ្រប់គ្រង*
*នៅតាមសាលា ក្បួនបង្រៀនផង ដើរតាមគន្លង*
*សិស្សមជ្ឈមណ្ឌល។*

*៥- យុគសម័យថ្មី យើងត្រូវឃ្មាតខ្មី រៀនឌីជីថល*
*រៀនប្រើ IT ដើម្បីបានផល ម៉ែឪសុំផ្តល់*
*សាលាជំនាន់ថ្មី។*

*តែងសម្រាប់ការចូលជួបគណៈកម្មការទី៧នៃព្រឹទ្ធសភា*
*សំណេរនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩*
*នៅតាមផ្លូវពីខេត្តព្រះសីហនុទៅខេត្តកំពត*

# កំណាព្យជូនពរកូនស្រី ហង់ វិមលា

(បទកាកគតិ)

១- សូមជូនពរជ័យ　សូមឱ្យកូនស្រី　ហង់ វិមលា
ទទួលជោគជ័យ　ក្នុងការសិក្សា　មានទាំងប្រាជ្ញា
និងចរិយាដែរ។

២- ទៅអាមេរិក　តែកូនកុំភ្លេច　គុណប្រទេសខ្មែរ
កូនបានធំធាត់　ដោយសារពុកម៉ែ　ជួយផ្គត់ផ្គង់ថែ
ជោគជ័យជីវិត។

សរសេរនៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩
វេលាម៉ោង៥:៣០នាទីល្ងាច

# វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ

(បទកុជឝ្តលីលា)

១- វិទ្យាស្ថានកំពង់ស្ពឺ គ្រឹះស្ថាននេះគឺ ពន្លឺវិជ្ជា។
បណ្តុះបណ្តាលឱ្យជា ពលរដ្ឋធូរធារ សទ្ធាថ្លៃថ្លា។
មានចំណេះមានប្រាជ្ញា បំណិនខ្លាំងក្លា ចរិយាសម្បត្តិ។

២- និស្សិតផលិតពូជសត្វ បន្ទែបង្កាត់ ពូជសត្វបក្សី។
បេះថ្នៃប្រឌិតប្រពៃ រិះរកអ្វីថ្មី ដើម្បីជាតិថ្កើង។
ដោះស្រាយបញ្ហាកើតឡើង ជីវភាពថ្កុំថ្កើង ដំឡើងយសស័ក្តិ។
សិស្សមានសមត្ថភាពប្រកបក្យ មានចិត្តស្មោះស្ម័គ្រ សហមេត្រី។

*តែងក្នុងឱកាសដំណើរទស្សនកិច្ចនៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ*
*ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៩*

# គរុសិស្សកំពង់ស្ពឺ
(បទព្រហ្មគីតិ)

១- ថ្ងៃនេះសប្បាយក្រៃ ឱកាសថ្ងៃបានជួបជុំ
ជាមួយអប្បមាទខ្ញុំ គរុក្រុមកំពង់ស្ពឺ។

២- ចូលរួមមើលប្រឡង ជាសិស្សច្បងផ្ដល់ពន្លឺ
ដោយទឹកចិត្តផ្កាលឈើ កំពង់ស្ពឺសូមប្រណម្យ។

៣- យើងខ្ញុំសូមសច្ចា គ្រប់គ្នាថានឹងខិតខំ
ធ្វើការឱ្យសក្តិសម បុត្រឧត្តមជាតិខេមរា។

៤- យើងខ្ញុំទទួលផល នឹងសងដល់ដែនពសុធា
ដើម្បីឱ្យប្រជា ក្លាយទៅជាធនធានពិត។

៥- កំណែទម្រង់ត្រូវ បំភ្លឺផ្លូវសិស្សនិស្សិត
កុលបុត្រខ្មែរយើងពិត ល្អប្រណីតមានរស្មី។

៦- សាលាគរុកោសល្យ ប្រឹងប្រែងផ្ដល់ចំណេះថ្មី
គរុសិស្សប្រុសស្រី មានភក្ដីចំពោះជាតិ។

ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង៥:៥០នាទីព្រឹក
តាមរថយន្តពីភ្នំពេញទៅកំពង់ស្ពឺ

# ក្រុងព្រះសីហនុ

(**បទពំនោល**)

១- រាជសីហ៍ស្រែកបែកវេហា ប្រាប់ដល់ខេមរា ឱ្យខិតខំរៀនសិក្សា។
២- ដើម្បីក្លាយជាកុលបុត្រ ធនធានបរិសុទ្ធ សក្តានុពលជាតិខ្មែរ។
៣- យើងត្រូវតាំងចិត្តឥតប្រែ រក្សាថ្នមថៃ លទ្ធផលកំណែទម្រង់។
៤- ដើម្បីឱ្យជាតិគង់វង្ស ឱ្យសមពូជពង្ស កុលបុត្រកសាងអង្គរ។
៥- បុរីសិង្ហបវរ ក្លាយជាទម្រ ឈ្នាន់សេដ្ឋកិច្ចឱជីថល។
៦- ដើម្បីបង្កើនទិន្នផល ពីកម្លាំងពល ទៅជាអេឡិចត្រូនិក។
៧- យើងខ្ញុំចង់ចាំមិនភ្លេច បំពេញភារកិច្ច តាមសតវត្សទី២១។
៨- បើបេះកុំបាច់ភ័យព្រួយ ផ្តល់ចិត្តជំនួយ នឹងជាប់ជាក់ជាមិនខាន។
៩- យើងខ្ញុំគឺជាធនធាន ដែលប្រសូតបាន ពីការកំណែទម្រង់។
១០- រៀនយកចំណេះផ្គត់ផ្គង់ ដើម្បីទ្រទ្រង់ កម្ពុជាយុគសម័យថ្មី។

ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង៦:៤៨នាទីព្រឹក
ហាងកាហ្វេចម្ការរនោង

# គរុសិស្សខេត្តកំពត

(បទបន្ទោលកាក)

១- ថ្លែងតាមទំនង ដំណើរដើមទងប្រឡង
កិច្ចការបម្រុង ធ្វើឱ្យអ្នកផងខ្លាំងក្លា។

២- ប្រឡងបានផល ធ្វើឱ្យយើងស្គាល់វិជ្ជា
ចំណេះធានា ជាទ្រព្យសក្ការខ្ពង់ខ្ពស់។

៣-ជំនួយអប្បមាទ ឱ្យជាតិខ្មែរឆ្លាតស័ក្តិយស
មានកិត្តិយសខ្ពស់ ឱ្យខេត្តយើងរស់ថ្កុំថ្កើង។

៤- កំពតដែនដី ផលដំណាំល្បីកើនឡើង
ខំលើកតម្កើង ផលភូមិសាស្ត្រថ្កើងឥតប្រៀប។

៥- ទុរេនឆ្ងាញ់ប្លែក ម្រេចកំពតឯកគុណភាព
អ្នកផងបានជ្រាប ឆ្នេរខ្សាច់មានប្រៀបលើសគេ។

៦- គរុសិស្សល្អ នាំជាតិបវរទាំងទ្វេ
ត្រូវបេះគ្នាន់គ្នេរ បន្តបុព្វេស្នាដៃ។

ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ ម៉ោង៩ព្រឹក
តាមរថយន្តពីខេត្តកំពង់ស្ពឺទៅខេត្តព្រះសីហនុ

# សាលាគរុកោសល្យខេត្តតាកែវ

(**បទជណ្តើរមាស**)

*១- កែវអើយតាកែវទីក្រុងចាស់ ទីក្រុងចំណាស់អង្គរបុរី*
*ថ្ងៃនេះមានភ័ព្វបានគាប់ជួបស្រស់ស្រី ភ្នំដាប្រិមប្រិយមោទភាពជាតិយើង។*

*២- ជំនុំជុំញាតិអប្បមាទ គរុសិស្សឆ្លាតជាតិបានថ្កុំថ្កើង*
*គ្រូមានកិត្តិយសព្រោះគុណភាពឡើង ត្រូវលើកតម្កើងឱ្យគ្រូយើងមានមុខមាត់។*

*៣- កំណែទម្រង់បណ្តុះគ្រូ ក្លាយជាគំរូមិនដែលភ្លាំងភ្លាត់*
*កម្មវិធីបែបបញ្ញត្តិសិស្សចេះស្ទាត់ ក្លាយជាបន្ទាត់សម្រាប់ការអប់រំថ្មី។*

*៤- គ្រូឧទ្ទេសមានចំណេះខ្ពស់ មានកិត្តិយសដ៏ល្អប្រពៃ*
*បង្រៀនតាមក្បួនគរុកោសល្យថ្មី និស្សិតប្រុសស្រីនឹងក្លាយជាពលរដ្ឋល្អ។*

*ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង២:០០រសៀល*
*តាមរថយន្តពីខេត្តព្រះសីហនុទៅខេត្តកំពត*

# គរុសិស្សកំពង់ធំ

(បទបទ្យាវត្ត)

១- ឱកំពង់ធំជំរំចិត្តខ្ញុំ ថ្ងៃនេះបានជុំជួបនឹងសិស្សគ្រូ
ដែលបានស្ម័គ្រស្មោះរួមចិត្តគិតគូរ ពង្រឹងគំរូកិច្ចការប្រឡង។

២- នេះជាទិវាសំខាន់ចម្បង យើងខ្ញុំបងៗផ្តល់កម្លាំងពិត
ដើម្បីចូលរួមការត្រួតពិនិត្យ រួបរួមគំនិតបម្រើប្រទេស។

៣- កំណែទម្រង់អប់រំពិសេស ឱ្យខ្លាំងចំណេះនាំមកគុណភាព
សូមឱ្យបេក្ខជនបានជ្រួតជ្រាប ដរាបរៀងរាបដើម្បីខ្មែរខ្លាំង។

៤- យុគសម័យថ្មីត្រូវការកម្លាំង ដែលហ៊ានតតាំងតាមផ្លូវប្រាជ្ញា
គំនិតត្រិះរិះនិងពិចារណា ដោះស្រាយបញ្ហាការអភិវឌ្ឍ។

៥- ឱភ្នំសន្ទុកគួរប្រតិព័ទ្ធ ស្ទឹងសែនមិនឃាត់ដួងចិត្តករី
ឱ្យធ្លាក់ចូលក្នុងអន្លង់ស្នេហ៍ស្រី ស្ពានកំពង់ក្តីជាសាក្សីខ្ញុំ។

៦- ឱកំពង់ធំជំរំចិត្តខ្ញុំ វេលាជួបជុំប្រណាម្យហត្ថា
ខ្ញុំប្តេជ្ញាចិត្តបម្រើរដ្ឋា យើងសហការជាកម្លាំងរស់។

ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង៧:៣០នាទីព្រឹក
ទីស្តីការក្រសួងអប់រំ យុវជន និងកីឡា

# គរុសិស្សខេត្តស្ទឹងត្រែង

(បទ ក ខ)

| | | | |
|---|---|---|---|
| ក | កំណែទម្រង់អប់រំ | ខ | ខិតហើយខំធ្វើការងារ |
| គ | គោរពតាមបទបញ្ញា | ឃ | ឃើញវេលាជាត្រឹមត្រូវ។ |
| ង | ងើបឈរធ្វើជាអប្បមាទ | ច | ចាត់ខ្ញុំបាទជិះតាមផ្លូវ |
| ឆ | ឆាប់ប្រាប់គរុសិស្សទៅ | ជ | ជួបគ្នានៅខេត្តស្ទឹងត្រែង។ |
| ឈ | ឈានរកចំណេះប្រាជ្ញា | ញ | ញឹមគ្រប់គ្នាហើយសម្តែង |
| ដ | ដើម្បីជាតិរស់ខែងរ៉ែង | ឋ | ឋិតនៅស្តែងសេសានទាប។ |
| ឌ | ឌិនដើម្បីការអប់រំ | ឍ | ឍាលធាត់ធំមានគុណភាព |
| ណ | ណែនាំអ្នកឱ្យសុភាព | ត | តាមរបៀបមានទ្រឹស្តី។ |
| ថ | ថាឡាបរិវាត់អើយ | ទ | ទាយំឆ្ងើយរកពិសី |
| ធ | ធម្មជាតិស្រស់ចិត្តបេតី | ន | នក្សត្រីទឹមនោរម្យ។ |
| ប | បញ្ចពិធកល្យាណ | ផ | ផុសប្រាជ្ញបានថ្កើងឧត្តម |
| ព | ពិតជាឱ្យខ្មែរសុខដុម | ភ | ភគវន្តមុនីនេះ។ |
| ម | មានតែត្រូវខំសិក្សា | យ | យកប្រាជ្ញជាមគ្គុទ្ទេសក៏ |
| រ | រង្វាន់ផ្តល់តាមនិទ្ទេស | ល | លោកិយនេះសែនអស្ចារ្យ។ |
| វ | វន្ទាព្រះរតនត្រៃ | ស | សូមជួយបីបាច់រក្សា |
| ហ | ហដ្ឋចិត្តជនខេមរា | ឡអ | ឡើងអារ្យធម៌ខ្មែរ។ |

*ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង១:២៦នាទីរសៀល*
*តាមរថយន្តពីខេត្តព្រះវិហារទៅខេត្តស្ទឹងត្រែង*

# គរុសិស្សខេត្តក្រចេះ

(បទ នមោ)

**ន** នៅក្រចេះជួបអប្បមាទ **មោ** មានឧិហាតជួយប្រឡង
**ពុ** ពូកែមានប្រាជ្ញផង **ទ្ធា** ធនចម្បងនៃជាតិខ្មែរ។
**យ** យសស័ក្តិសមរណ្តំចិត្ត **សិ** សមប្រណីតខ្លាំងពូកែ
**ទ្ធំ** ធនជានមានគុណភាពដែរ **អ** ឱ្យជាតិខ្មែរថ្កុំថ្កើងថ្កាន។
**អា** អានុភាពនៃចំណេះ **ឥ** ឥតគេបេះបន្ទំបាន
**ឦ** ឱ្យរួចផុតពីខ្លៅសាមាន្យ **ឪ** អស់សន្តានបានមុខមាត់។
**ឧ** ឱរំដួលខេត្តក្រចេះ **ឩ** អាចអ្នកចេះដាប់មិនភ្ជាត់
**ឫ** ឫទ្ធានុភាពយ៉ាងស្ទាត់ **ឬ** រឹតប្រតិព័ទ្ធក្នុងជីវិត។
**ឭ** លាក់លំបាកមិនរាថា **ឮ** លុះវាសនាចារទុកពិត
**អាំ** អង់អាចអប់រំរួមរឹត អះអាងគំនិតគិតប្រមាណ។
**ឯ** អំពើល្អគរុសិស្ស **ឱ** ឱ្យប្រតិដ្ឋអធិស្ឋាន
**អុំ** អំណឹះតទៅសូមឱ្យបាន ជោគជ័យគ្រប់ប្រាណការសិក្សា។

*ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង៨:៣០នាទីយប់*
*ខេត្តស្ទឹងត្រែង*

# គរុសិស្សខេត្តកំពង់ចាម

(***បទ សិង្ហតោលេងកន្ទុយ***)

*ការប្រឡង សញ្ញាបត្រ ទុតិយទ:*
*បានឱ្យអ្នក ខំសិក្សា រៀនរួសរាន់*
*គោរពគ្រូ មានវិន័យ ជោគជ័យជាន់*
*បង្រៀនគ្រាន់ សិស្សប្រិតប្រៀង ឥតអស់អែក។*

*អប្បមាទ ធ្វើកិច្ចការ ផ្គាប់ផ្គូផ្គង*
*តាមគន្លង ត្រូវខំធ្វើ កុំកលកែក*
*អនាគត កូនខ្មែរល្អ ប្រឹងប្រែងប្រែក*
*ដើម្បីស្អែក កម្ពុជា ថ្កុំថ្កើងថ្កាន។*

*គោរពតាម បទបញ្ញត្តិ ខ្នាន់ខ្នាប់ខ្លួន*
*ឱមាសស្ងួន បំពេញតាម ហ្មឹងម៉ាត់មៀង*
*ឱ្យសម្រេច ភារកិច្ច ព្រោះព្រមព្រៀង*
*គ្រូគរកៀង កត្តិយស ខ្ពស់ខ្ពង់ខ្ពិត។*

*កំពង់ចាម វត្តនគរ ល្បីល្បាញល្បាត*
*គរុឆ្លាត ឆ្នុំហើយស្អាត ប្រាជ្ញប្រិមប្រិយ*
*បានចូលរួម ធ្វើអប្បមាទ ស្មោះស្ម័គ្រស្មិត*
*កម្លាំងពិត ជាតិខ្មែរយើង វែងរុងរឿង។*

*ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង៩:៣០នាទីព្រឹក*
*តាមរថយន្តពីខេត្តក្រចេះទៅខេត្តកំពង់ចាម*

# គរុសិស្សខេត្តព្រៃវែង
(បទព្រហ្មគីតិ)

១- សុភមស្តុស្ដួ ស្ដីមង្គលស្រីសទ្ធា
បេស្តាជយ្យាទា រេកទិវានក្ខត្តឫក្ស។[2]

២- ខ្ញុំជារដ្ឋមន្ត្រី ខំឃ្មាតខ្មីងើបពីព្រឹក
សោមនស្សជាពន្លឹក ហង្សាទឹកជូនណារ៉ុន។

៣- បានជួបនឹងអប្បមាទ មានមាយាទល្អពេកពន់
ប្រឡងមិនទម្រន់ វ័យតរុណសុចរិតក្រៃ។

៤- មកដល់ខេត្តព្រៃវែង ជាកន្លែងល្អប្រពៃ
គរុសិស្សលកលៃ បេះកៃខែការប្រឡង។៚

(បទភាគគតិ)

៥- ខ្ញុំសូមសរសើរ ដោយចិត្តស្មោះស្មើ ការប្ដេជ្ញាចិត្ត
បុគ្គលិកអប់រំ វេញធ្នុង់រួមរឹត តាមការប្រព្រឹត្ត
ឱ្យជាតិថ្កុំថ្កើង។

៦- សូមរតនត្រ័យ ជួយឱ្យពរជ័យ ដល់អប្បមាទយើង
មើលការប្រឡង ទប់ស្កាត់ទំនើង ប្រទេសរុងរឿង
ព្រោះពលរដ្ឋល្អ។

ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩

---

2 ភាសាខ្មែរសម័យកណ្ដាល។

# គរុសិស្សខេត្តស្វាយរៀង
(បទព្រហ្មគីតិ)

១- សុភមស្តុស្ត ស្តីមង្គលស្រីសទ្ធា
បេស្តាជយ្យាទា វេកទិវានក្ខត្តប្ញក្ស។

២- ខ្ញុំមានចិត្តបីតិ ដាស់សតិនឹករឭក
មកជួបដើម្បីប្រឹ ក្សារៀបឫកការប្រឡង។

៣- គរុសិស្សប្រុសស្រី ត្រូវភក្តីតាមបំណង
ពង្រឹងគុណភាពផង តាមគន្លងកែទម្រង់។

៤- សិស្សយើងខំសិក្សា យកវិជ្ជាលើកជ្រោងទង់
ពុទ្ធិល្អផ្លូវផង់ ជ័យូរលង់ជាតិពណ្ណរាយ។

៥- ស្វាយរៀងជាបុរី មានឈ្មោះល្បីល្បាញសុសសាយ
ខ្ញុំក៏មានអ្នកម្តាយ និងសម្ពាយនៅខេត្តនេះ។

៦- យើងខំប្រឹងធ្វើការ ជនខេមរាមានចំណេះ
បំណិនមិនរលេះ ចោរមិនបេះប្លន់យកបាន។

៧- យើងបានទទួលផល ដែលបន្សល់មិនទឹកស្មាន
កម្ពុជានឹងមាន វិបុលផលរុងរឿងអើយ។

ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង១២:១៦នាទី

# គរុសិស្សខេត្តកណ្ដាល

(បទពាក្យ ៩ បែបជាប់ទង)

១- ជាតិជាគ្រូ ស៊ូខំប្រឹង ដឹងខ្លាំងក្លា
ឱ្យប្រជា ជានាចេះ រិះរករៀន
ហ៊ានលះបង់ រង់ចាំពេល វេលាមាន
សង្គមបាន ក្សាន្តក្សេមសុខ មុខជាស្គាល់។

២- ពេលទៅរៀន ហ៊ានធ្វើការ ណាទាំងអស់
អប្បមាទស្មោះ ដោះទម្ងន់ ធ្ងន់លើសដី
ទាំងប្រុសស្រី វ័យតរុណ ពន់មិនស្ដី
ហើយគ្មានអ្វី ល្បីជាងគ្រូ ស៊ូឱ្យល្អ។

៣- ខេត្តកណ្ដាល កាលពីមុន រណ្ដំចិត្ត
ខ្ញុំស្នេហ៍ស្និទ្ធ ពិតចិន្ដា ថ្វាថ្លើមពិត
ត្រូវខំខិត គិតយ៉ាងណា ការមិនអៀន
ខ្ញុំធ្លាប់រៀន មានចំណេះ ចេះបានខ្ពស់។

ថ្ងៃទី១ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង៥:០០នាទីល្ងាច
ខ្ញុំជាអតីតសិស្សសាលាបឋមសិក្សាក្រពើហា
និងវិទ្យាល័យតាខ្មៅ មុនឆ្នាំ១៩៧៥

# ជូនពរបេក្ខជនប្រឡង

(បទពាក្យ ៧ បែបគោព័ន្ធស្ទឹង)

១- ថ្ងៃប្រឡងបានមកដល់ហើយ    ហើយបេក្ខជនអើយចូររួសរាន់
រាន់ពេលរូតរះទៅឱ្យទាន់    ទាន់នៅក្មេងគ្រាន់ប្រឡងជាប់។

២- ជាប់បានទាល់តែបេក្ខជនចេះ    ចេះពីរៀនត្រិះវិជ្ជាទ្រព្យ
ទ្រព្យលួចមិនបានប្រសើរគាប់    គប្បីបេក្ខជនគោរពច្បាប់។

៣- ច្បាប់ហាមយកទូរស័ព្ទដៃចូល    ចូលត្រូវប្រមូលឯកសារប្រាប់
ប្រាប់មុនត្រូវពឹងលើចំណេះ    ចេះទើបបេក្ខជនប្រឡងជាប់។

៤- ជាប់នាំមកនូវកិត្តិយស    យសស័ក្តិបានព្រោះរៀនចេះជាប់
ជាប់កុំភ្លេចគុណគ្រូដែលធ្លាប់    ធ្លាប់បង្រៀនសិស្សជោគជ័យជូន។

៥- ជូនពរបេក្ខជនបានជោគជ័យ    ជ័យមានអត្ថន័យណាស់ប្អូនៗ
ប្អូនមានសុខភាពខ្លាំងមាំមួន    មួនមានកម្លាំងដូចគជសារ។

ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩

# ប្រធានមណ្ឌល

(*បទ កាកគតិ*)

១- ប្រធានមណ្ឌល ការងារច្រើនដល់ ជារដ្ឋមន្ត្រី
ប្រចាំមណ្ឌល ធ្វើអស់អ្វីៗ គ្រប់គ្រងមន្ត្រី
តាមកាតព្វកិច្ច។

២- បំពេញការងារ ដើម្បីកម្ពុជា តាមភារកិច្ច
ដើម្បីកូនខ្មែរ ចងចាំមិនភ្លេច ជាបូជនីយកិច្ច
មូលធនជាតិកើន។

៣- ពូជខ្មែរអង្គរ ដួងចិត្តស្មោះសរ មោទនចម្រើន
ជួយបេក្ខជន ប្រឡងបង្កើន ចំណេះចេះច្រើន
ចម្រើនរដ្ឋា។

៤- ជួយអនុរក្ស បម្រើដោយស្ម័គ្រ ដើម្បីខេមរា
មានឫទ្ធិអំណាច កោតខ្លាចរក្សា ខ្ញុំសូមប្រាថ្នា
កើតជាខ្មែរទៀត។

៥- បួងសួងទេវតា សូមជួយរក្សា កុំបីឃ្លៀងឃ្លាត
បានសុខសិរី ជួបជុំផៅញាតិ ជួបគ្នាម្តងទៀត
កម្ពុជារុងរឿង។

*ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង៦:៤១ព្រឹក*

# ជំនួយការអប្បមាទ

(បទពាក្យ ៧)

១- ប្រាសាទអណ្តែតលើវេហា ដាស់ជនខេមរាឱ្យចងចាំ
ថាខ្មែរពីមុនតាមចំណាំ ជាពូជធ្លាប់ខ្លាំងមានតេជះ។

២- ខ្មែរខ្លាំងដោយខ្មែរមានចំណេះ ខ្មែរចេះរិះគ្រិះមានជម្នះ
សិក្សារៀនសូត្រយ៉ាងរូតរះ ហើយធ្លាប់ច្បាំងឈ្នះសត្រូវមារ។

៣- គរុសិស្សចូរអ្នកចងចាំថា ប្រជាខេមរាគ្រប់ៗគ្នា
កំពុងរង់ចាំគ្រប់វេលា ឱ្យអ្នកធានាមើលប្រឡង។

៤- គរុសិស្សជាជំនួយអប្បមាទ គុណភាពស្អំស្អាតជាចម្បង
កំណែទម្រង់ការប្រឡង បេក្ខជនត្រាប់ត្រង់តាមបញ្ញត្តិ។

# អនុរក្សក្នុងពេលប្រឡង

(បទសិង្ហតោលេងកន្ទុយ)

ការប្រឡង សញ្ញាបត្រ ទុតិយទៈ
បានឱ្យអ្នក ខំសិក្សា រិះរករៀន
គោរពគ្រូ មានវិន័យ ជោគជ័យជាន
គ្រូបង្រៀន សិស្សប្រិតប្រៀង ឥតអស់អែក។

អនុរក្ស ធ្វើកិច្ចការ ផ្គាប់ផ្គូផ្គង
កិច្ចចម្បង ត្រូវខំធ្វើ កុំកលកែក
អនាគត កូនខ្មែរល្អ ប្រឹងប្រែងប្រែក
ដើម្បីស្អែក កម្ពុជា ថ្កុំថ្កើងថ្កាន។

គោរពតាម បទបញ្ញត្តិ ខ្ជីខ្ជាប់ខ្លួន
ឱមាសស្ងួន បំពេញតាម ហ្មឹងម៉ាត់មាន
ឱ្យសម្រេច ភារកិច្ច បីបមបាន
ទើបគ្រូមាន កិត្តិយស ខ្ពស់ខ្ពង់ខ្ពិត។

# អាទិភាពទាំង ៨
# នៃកំណែទម្រង់វិស័យអប់រំ

(*បទកាកគតិ*)

១- សព្វមស្តុ សួស្តីស្រីសុ- កមង្គលជ័យ
គ្រិស្តសករាជ ទ្វិសហស្សៃ ឱនវិសតី
ពហុលចេស្តា។[3]

២- ពូជពង្សអំបូរ ធ្លាប់ធ្វើជាគ្រូ បម្រើរដ្ឋា
ព្រះនាមហង់ ជួន ជាឆ្មើមបិតា ម៉ែន សាអ៊ុនណា
មាតាខ្ញុំថ្លៃ។

៣- នាមដើមហង់ជួន ណារ៉ុន ជាប់ជួន អង្គខ្ញុំឯងនៃ
នាងប៉ែន វិមល ភរិយាករី ជារដ្ឋមន្ត្រី
ក្រសួងអប់រំ។

៤- ជាសេដ្ឋវិទូ វិភាគគំរូ គិតគូរសមរម្យ
រៀបចំថវិកា កិច្ចការគួបផ្សំ ធ្វើមិនលំៗ
លេខាធិការ។

៥- លុះបានជោគជ័យ មង្គលសួស្តី អគ្គសេនា
សម្តេចតែងតាំង ឱ្យក្លាយទៅជា រដ្ឋមន្ត្រីនា
ក្រសួងអប់រំ។

៦- កំណែទម្រង់ អប់រំកំពុង បំពេញពូនជ្រំ
មានអាទិភាព ប្រាំបីខិតខំ កូនខ្មែរចេះចំ
ជាធនធានល្អ។

៧- ទីមួយ **ប្រឡង** កិច្ចការចម្បង យុត្តិធម៌កម្រ

[3] ភាសាបាលី។

ឱ្យសិស្សខំរៀន គ្រូខំគាំទ្រ វិជ្ជាបវរ
ល្អជាពេកពន់។

៨- ទីពីរជា **គ្រូ** បង្រៀនតស៊ូ ទោះការស្រោលធ្ងន់
បំពេញបំប៉ន បន្ថែមរូបមន្ត ឱហាតអត់ធន់
ពង្រឹងចំណេះ។

៩- ទីបី **គុណភាព** កម្រិតខ្ពស់ទាប ប្រឹងប្រែងឱ្យចេះ
ទទួលខុសត្រូវ មិនធ្វេសប្រហែស លើកស្ទួយតម្រិះ
តាមផែនការជាតិ។

១០- ទីបួន **ជំនាញ** ឯកទេសទាក់ទាញ ប្រយោជន៍ជូនញាតិ
ចេះឱ្យប្រាកដ ហ៊ានប្រជែងទៀត លើអន្តរជាតិ
យកផ្សារពលកម្ម។

១១- ប្រាំ **ថវិកា** ត្រូវមានផែនការ គម្រោងសកម្ម
គ្រប់គ្រងបានល្អ ប្រើប្រាស់តាមឆ្នាំ ជំរុញប្រចាំ
ប្រសិទ្ធភាពខ្ពស់។

១២- **ឧត្តមសិក្សា** ទីប្រាំមួយថា ប្រជែងកេរ្តិ៍ឈ្មោះ
បណ្តុះធនធាន ចំណេះដឹងខ្ពស់ ឧត្តមសមយស
មូលធនមនុស្សថ្មី។

១៣-ប្រាំពីរ **កីឡា** អប់រំកាយា សុខភាពវិស័យ
បណ្តុះដើងឯក ដណ្តើមជោគជ័យ ឥស្សរយសថ្លៃ
កម្ពុជាឧត្តម។

១៤- ប្រាំបីសោតណា មាន**ក្រុមប្រឹក្សា** ស្រាវជ្រាវប្រជុំ
ចក្ខុវិស័យ យុទ្ធសាស្ត្រជាធំ ធនាគារផ្តុំ
ខួរក្បាលអប់រំ។

១៥- កំណាត់ចំណាំ សសរស្តម្ភប្រាំ វិនិយោគអប់រំ
មូលធនមនុស្សខ្លាំង ប្រទេសថ្កើងថ្កុំ សេដ្ឋកិច្ចជាត់ធំ
កម្ពុជាក្សេមក្សាន្ត។

# គ្រូជាមូលដ្ឋានគ្រឹះ
# នៃយុគសម័យឌីជីថល

(*បទពាក្យ ៩*)

| | | | |
|---|---|---|---|
| ១- | *ការអប់រំ* | *យុគសម័យ* | *ឌីជីថល* |
| | *គ្រូត្រូវផ្ដល់* | *ពលរដ្ឋល្អ* | *មានពុទ្ធិ* |
| | *មានបំណិន* | *មានចរិយា* | *មានឫទ្ធិ* |
| | *សមិទ្ធិ* | *ចូលរួមសាង* | *សេដ្ឋកិច្ចជាតិ។* |
| ២- | *គ្រូត្រូវមាន* | *សមត្ថភាពខ្លាំង* | *គុណវុឌ្ឍិខ្ពស់* |
| | *សីលធម៌រស់* | *នៅស្អាតស្អំ* | *យ៉ាងខ្មីឃ្មាត* |
| | *អភិវឌ្ឍ* | *វិជ្ជាជី* | *វៈវៃឆ្លាត* |
| | *ដែលមិនឃ្លាត* | *ពីស្ដង់ដារ* | *គ្រូបង្រៀន។* |
| ៣- | *ត្រូវស្គាល់សិស្ស* | *ស្គាល់កម្មវិ* | *ធីសិក្សា* |
| | *យល់ខ្លឹមសារ* | *យល់បញ្ញត្តិ* | *ជួយសិស្សរៀន* |
| | *វិធីសាស្ត្រ* | *ចេះឱ្យច្បាស់* | *របៀបរៀន* |
| | *សិស្សចេះរៀន* | *ស្វ័យសិក្សា* | *តាមសម្បទី។*[4] |
| ៤- | *កិច្ចតែងការ* | *បរិក្ខារ* | *វាយតម្លៃ* |
| | *គ្រូសម័យ* | *ឌីជីថល* | *ចេះអាយធី* (*IT*) |
| | *អនុវត្ត* | *ការបង្រៀន* | *ICT* |
| | *មានវិធី* | *សាស្ត្រគ្មានពីរ* | *សិស្សរៀនវៃ។* |
| ៥- | *មានសីលធម៌* | *ខ្ពស់បវរ* | *មានស្វ័យភាព* |
| | *គ្រូសុភាព* | *គ្រប់គ្រងថ្នាក់* | *រៀនឆ្លាតវៃ* |

4 *សម្បទា* (*សរសេរឱ្យចាប់ដួន*)។

| | | | |
|---|---|---|---|
| | ប្រើឧបករណ៍ | បច្ចេកវិ | ទ្យាប្រពៃ |
| | ផ្ដល់រស្មី | ពុទ្ធិថ្មី | ជាតិយើងរស់។ |
| ៦- | មានប្រាជ្ញា | មានវិជ្ជា | ការអប់រំ |
| | មានស្មៀតផ្សំ | ចិត្ត-គរុ | កោសល្យខ្ពស់ |
| | អនុមានរួម | អនុមានញែក | តក្កទស្សន៍ |
| | សិស្សចេះព្រោះ | ចេះដោះស្រាយ | បង្កើតថ្មី។ |
| ៧- | បង្រៀនសិស្ស | ឱ្យត្រិះរិះ | ពិចារណា |
| | ចេះខ្លឹមសារ | ចេះបញ្ញត្តិ | និងទ្រឹស្តី |
| | ចេះវិភាគ | វាយតម្លៃ | ស្រាវជ្រាវថ្មី |
| | មានវិន័យ | មានសម្ដី | ជាអ្នកប្រាជ្ញ។ |
| ៨- | គ្រូគឺជា | មគ្គុទ្ទេសក៍ | ជួយប្រាប់ផ្លូវ |
| | គ្រូយើងត្រូវ | ចេះស្រាវជ្រាវ | តែមិនកាច |
| | សិស្សអាចយល់ | មានគុណភាព | មិនភ័យខ្លាច |
| | មិនកោងកាច | ចេះគោរព | គ្រូបាធ្យាយ។ |
| ៩- | គ្រូត្រូវចេះ | អក្ខរកម្ម | ឌីជីថល |
| | មានកោសល្យ | ចេះបង្រៀន | ឱ្យសប្បាយ |
| | រៀបគម្រោង | ស្វ័យសិក្សា | និបរិយាយ |
| | និងវាយតម្លៃ | តម្លៃសិស្ស | បានសុក្រឹត។ |
| ១០- | យុគសម័យ | ឌីជីថល | ត្រូវការគ្រូ |
| | ជាគំរូ | ដល់សង្គម | គ្មានវិបរិត |
| | គ្រូត្រូវមាន | គុណភាពខ្ពស់ | យសមានពិត |
| | តែត្រូវខិត | ខំពង្រឹង | ខ្លួនជានិច្ច។ |

ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៩

# *Partir c'est mourir un peu!*

*1- Comment te dire adieu, Vimuolea!*
*Comment regarder tes yeux pour dire,*
*Comment se rappeller des moments heureux et pires,*
*Comment t'accompagner à Columbia.*

*2. Il est temps de pousser les ailes,*
*Il est temps de voler dans le ciel,*
*Il est temps de goûter le miel,*
*Il est temps de partir pêle-mêle.*

*3. Une francophone engagée,*
*Nous te présentons nos souhaits,*
*Que du Bonheur et du succès,*
*Que de la gloire à ta rentrée.*

*(Le 6 août 2019)*

# បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

*បណ្ឌិតសភាចារ្យ* ***ហង់ជួន ណារ៉ុន*** *បច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(SNEC) ក្នុងនីតិកាលទី៦នៃរាជរដ្ឋាភិបាលកម្ពុជា។*

*លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់នៅឆ្នាំ១៩៨៨ និងបណ្ឌិតនៅឆ្នាំ១៩៩១ ផ្នែកសេដ្ឋកិច្ចអន្តរជាតិពីវិទ្យាស្ថានទំនាក់ទំនងអន្តរ-ជាតិក្រុងម៉ូស្គូ ព្រមទាំងសញ្ញាបត្រជាន់ខ្ពស់ផ្នែកធានារ៉ាប់រងពីវិទ្យាស្ថានធានារ៉ាប់រង( CII) ប្រទេសអង់គ្លេស និងវិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី (MII)។ នៅឆ្នាំ២០១២ លោកបណ្ឌិតទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រអន្តរជាតិពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅកម្ពុជា និងពីសាកលវិទ្យាល័យLyon II នៃសាធារណរដ្ឋបារាំង ព្រមទាំងទទួលបានវិញ្ញាបនបត្រផ្នែកនីតិសមុទ្រពីបណ្ឌិត្យសភា Rhodes ផ្នែកនីតិសាស្ត្រ និងគោលនយោបាយសមុទ្រ។ នៅឆ្នាំ២០១៨ លោកបណ្ឌិតទទួលបានសញ្ញាបត្របណ្ឌិតផ្នែកអប់រំពីសាកលវិទ្យាល័យចូឡាឡុងកន។*

*លោកបណ្ឌិតធ្លាប់បានបម្រើការងារក្នុងបេសកកម្មការទូត និងក្នុងវិទ្យាស្ថានស្រាវជ្រាវ ជាអ្នកវិភាគនយោបាយ និងសេដ្ឋកិច្ច។ ចាប់តាំងពីឆ្នាំ១៩៩៩មក លោកបណ្ឌិតបានចូលបម្រើការងារក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទទួលបន្ទុកការងារសំខាន់ៗរួមមាន អ្នកសម្របសម្រួលការងារស្រាវជ្រាវនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងជាអនុប្រធានទី១នៃនាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ។ បន្ទាប់មក ក្នុងឆ្នាំ២០០១ លោកបណ្ឌិតបានត្រូវតែងតាំងជាអគ្គលេខាធិការរងទទួលបន្ទុកគោលនយោបាយរួមមាន គោលនយោបាយ*

សេដ្ឋកិច្ច សារពើពន្ធ ហិរញ្ញវត្ថុ កិច្ចការអាស៊ាន ឧស្សាហកម្មហិរញ្ញវត្ថុ ការវិភាគសេដ្ឋកិច្ច និងទទួលបន្ទុកក្នុងការសម្របសម្រួលជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក(World Bank)។

ពីឆ្នាំ២០០៤ដល់ឆ្នាំ២០១០ លោកបណ្ឌិតត្រូវបានតែងតាំងជាអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លោកបណ្ឌិតធ្លាប់ចូលរួមកិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្ដាលអាស៊ានបូកបី ពីឆ្នាំ២០០០ដល់២០១០។ ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៣ លោកត្រូវបានតែងតាំងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងតួនាទីនេះ លោកធ្លាប់ធ្វើជាតំណាងប្រទេសកម្ពុជា ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្ដាល G20 ក្នុងឋានៈដែលប្រទេសកម្ពុជាជាប្រធានអាស៊ាន នៅឆ្នាំ២០១២។ លោកបណ្ឌិតក៏បម្រើការងារជាអ្នកសម្របសម្រួលកិច្ចពិភាក្សាគោលនយោបាយរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយធនាអភិវឌ្ឍន៍អាស៊ី(ADB) មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក(World Bank)។

ក្នុងតំណែងជាអនុប្រធានប្រចាំការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) ដែលជាស្ថាប័នខាងផ្នែកគោលនយោបាយសេដ្ឋកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជា លោកបណ្ឌិតបានសរសេរឯកសារគោលនយោបាយជាច្រើន និងបានអមដំណើរ សម្ដេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងសន្និសិទអន្តរជាតិ ដូចជាមហាសន្និបាតអង្គការសហប្រជាជាតិ ចលនាមិនចូលបក្សសម្ព័ន្ធ កិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំកំពូលអាស៊ីបូព៌ា និងវេទិកាអន្តរជាតិជាច្រើនទៀត។

លោកបណ្ឌិតបាននិពន្ធសៀវភៅជាច្រើនក្បាល ជាភាសាខ្មែរ អង់គ្លេស និងបារាំង ស្ដីអំពីការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា និងហិរញ្ញវត្ថុសាធារណៈ ហើយស្នាដៃចុងក្រោយ ក្រោមចំណងជើងថា «Cambodian Economy:

Charting the Course for a Bright Future» ត្រូវបានជ្រើសរើសបោះ-ពុម្ពផ្សាយ ដោយវិទ្យាស្ថានសិក្សាអាស៊ីអាគ្នេយ៍(ISEAS) នៃប្រទេសសិង្ហបុរី។ ស្នាដៃចុងក្រោយរបស់លោក គឺ «ប្រវត្តិសាស្ត្រកម្ពុជាក្នុងបរិបទសកលោក»។

# ស្នាដៃរបស់អ្នកនិពន្ធ

១- L'Économie du Cambodge : La lutte pour le développement, 2005

២- Essais économiques, 2007

៣- Les finances publiques du Cambodge, 2007

៤- Cambodia: Recent Macroeconomic and Financial Sector Development, 2008

៥- Three Essays on Macroeconomic Management of Cambodia, 2008

៦- Introduction to Insurance, 2008

៧- ម៉ាក្រូសេដ្ឋកិច្ច - ឆ្នាំ២០០៩

៨- Public Finance in Cambodia, 2009

៩- ហិរញ្ញវត្ថុសាធារណៈ - ឆ្នាំ២០០៩

១០- ប្រាសាទព្រះវិហារ - ឆ្នាំ២០០៩

១១- Cambodian Economy: Chartering the Course of a Brighter Future. A Survey of Progress, Problems and Prospects, 2009

១២- L'économie du Cambodge: Nouvelles frontières du développement socio-économique, 2010

១៣- Regards sur le différend maritime khméro-thaïlandais à la lumière de la jurisprudence internationale, 2012

១៤- ទស្សនាទានស្តីពីវិវាទព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡង់ដ៍ ក្នុងបរិបទនៃយុត្តិការអន្តរជាតិ - ឆ្នាំ២០១៣

១៥- សេដ្ឋកិច្ចកម្ពុជា ៖ មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង ៖ វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត - ឆ្នាំ២០១៥

១៦- កំណែទម្រង់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ៖ មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព - ឆ្នាំ២០១៦
១៧- គោលនយោបាយទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសនៃប្រទេសកម្ពុជា នាសម័យទំនើបនៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា( ទសវត្សរ៍ឆ្នាំ១៩៨០) - ឆ្នាំ២០១៧
១៨- នីតិអន្តរជាតិសេដ្ឋកិច្ច - ឆ្នាំ២០១៧
១៩- *Series of Lectures in Public International Law, 2018*
២០- សិក្សាសង្ខេបស្តីពីទស្សនវិជ្ជា - ឆ្នាំ២០១៨
២១- *Droit International Économique, 2018*
២២- *Education Reform in Cambodia, 2018*
២៣-វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរក្នុងការលើកកម្ពស់អំណាននៅកម្ពុជា - ឆ្នាំ២០១៩
២៤- ប្រវត្តិសាស្ត្រកម្ពុជាក្នុងបរិបទសកលោក - ឆ្នាំ២០១៩



កំណាព្យខ្មែរមានប្រវត្តិដ៏យូរលង់ណាស់មកហើយ។ សិលាចារឹកចាប់ពីសតវត្សទី៦ដល់ទី១២ជាភាសាសំស្ក្រឹត សុទ្ធតែរៀបរៀងជាពាក្យកាព្យ ដែលហៅថា «កាវ្យៈ»។ នៅសតវត្សទី១០ កំណាព្យភាសាសំស្ក្រឹតខ្មែរឈានដល់ចំណុចកំពូល។ វណ្ណកម្មអក្សរសិល្ប៍កំណាព្យខ្មែរកណ្ដាលចាប់ពីសតវត្សទី១៥ដល់ទី១៨ មានរឿង«រាមកេរ្តិ៍» និង«ល្បើកអង្គរវត្ត» ១៦២០)។ សិលាចារឹកជ័យ នន្ទ (១៧០១) តែងជាបទព្រហ្មគីតិ ភុជង្គលីលា និងកាកគតិ។ អក្សរសិល្ប៍កំណាព្យភាសាខ្មែរសម័យទំនើបឈានដល់ចំណុចកំពូលនៅចុងសតវត្សទី១៩ និងដើមសតវត្សទី២០ ដូចជារឿង«សព្វសិទ្ធិ» (១៨៩៩) និពន្ធដោយលោក ហ៊ឹនភក្ដីអក្សរ តន់ និងរឿង«ទុំទាវ» (១៩១៥) ដោយព្រះបទុមថេរសោម។ ដូច្នេះ កំណាព្យខ្មែរ គឺជាបេតិកភណ្ឌជាតិដ៏សំខាន់ដែលបុព្វបុរសខ្មែរបន្សល់ទុក ហើយកូនខ្មែរជំនាន់ក្រោយមានកាតព្វកិច្ចអភិរក្ស និងអភិវឌ្ឍបន្តទៀត។

ISBN: 978 99950 02 76 3

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia